ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

# បម្រាម
# មិនឲ្យមានគ្រឿងអាវុធ

ដោយមិនគិតពី អាយុ ឬកម្រិតថ្នាក់ ច្បាប់របស់រដ្ឋផិនស៊ីលវេញ៉ាតម្រូវថា សិស្សណាដែលមាន **អាវុធ** ក្នុងខ្លួន ពេលចូលរួមក្នុងកម្មវិធី ឬសកម្មភាពរបស់សាលា ឬពេលធ្វើដំណើរទៅឬមកពីសាលា ឬពីកម្មវិធី ឬសកម្មភាពរបស់សាលា (រួមទាំង ក្នុងរថយន្តសាលា និងរថយន្តសាធារណៈ) នឹងត្រូវគេ **ចាប់ខ្លួន និងបណ្ដេញចេញ** ពីក្រសួងអប់រំ អស់រយៈពេលយ៉ាងហោចណាស់មួយឆ្នាំ។

ច្បាប់បានឲ្យនិយមន័យទៅលើ **អាវុធ** ដូចជា «កាំបិតគ្រប់បែបយ៉ាង ឧបករណ៍ ឬប្រដាប់កាត់អ្វីមួយ កាំភ្លើង កាំភ្លើងខ្លី កាំភ្លើងវែង និងគ្រឿងប្រដាប់ផ្សេងៗទៀត ដែលអាចធ្វើឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ។» ច្បាប់មិនបានតម្រូវថា សិស្សបានប្រើ ឬព្យាយាមប្រើអាវុធនោះទេ មុនពេលគេចាប់ខ្លួន ឬបណ្ដេញចេញ។ ម្យ៉ាងវិញទៀត ការមានអាវុធសម្រាប់ការពារខ្លួន ក៏គេមិនលើកលែង ឲ្យនៅក្នុងខដែលមានចែងក្នុងច្បាប់នេះដែរ។ ការមានអាវុធ រួមទាំង អាវុធដែលគេបានរកឃើញក្នុងខ្លួន ព្រមទាំង ក្នុងសំពៀតដាក់សៀវភៅ ក្នុងថតតុ ឬក្នុងទូដាក់សម្ភារៈនៅសាលា។

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer